សិក្ខាសាលា

# ទស្សនាទានស្ដីពីទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០

អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃទី ខែតុលា ឆ្នាំ២០១៥

# មាតិកានុក្រម

១. ទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកា

២. ផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកា

៣. កត្តាកំណត់ជោគជ័យ

៤. សន្និដ្ឋាន

# ១. ទិសដៅយុទ្ធសាស្ត្រ

# ការកែទម្រង់ប្រព័ន្ធថវិកា គឺជាស្នូល នៃដំណាក់កាលទី៣ និងទី៤ នៃ ក.ហ.ស.

២០០៤-២០២៥

ទី៤ ÷ ២០២១-២០២៥

**គណនេយ្យភាពសមិទ្ធកម្ម** ÷ ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម (ជំហានទី ៤)

ទី៣ ÷ ២០១៦-២០២០

**ថវិកាផ្សារភ្ជាប់ជាមួយគោលនយោបាយ** ÷ ការកែទម្រង់ប្រព័ន្ធថវិកា (ជំហានទី ៣)
ផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី អង្គភាពថវិកា

ទី២ ÷ ២០០៩-២០១៥

**គណនេយ្យភាពហិរញ្ញវត្ថុ** ÷ ប្លង់គណនីថ្មី មាតិកាថវិកាថ្មី អង្គភាពថវិកា (ជំហានទី ២)
ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ

ទី១ ÷ ២០០៤-២០០៨

**ភាពជឿទុកចិត្តលើថវិកា** ÷ ពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល (ជំហានទី ១)
គណនីទោលរតនាគារជាតិ និងការគ្រប់គ្រងសាច់ប្រាក់

# ១. ទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកា (១)

## តើយើងត្រូវធ្វើដំណើរទៅណា?

### គោលដៅគន្លឹះ ២ នៃការកែទម្រង់ប្រព័ន្ធថវិកា គឺ៖

- បង្កើនវិន័យក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (តុល្យភាព/ចីរភាព) បង្កើនប្រសិទ្ធភាពវិភាជ (វិភាជចំគោលដៅអាទិភាព) និងបង្កើនប្រសិទ្ធភាពបច្ចេកទេស (ចំណាយប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព)។
- ការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមធ្យការ ទៅប្រព័ន្ធថវិកា និងការគ្រប់គ្រង ដែលផ្តោតលើធាតុចេញ (លទ្ធផល និងសមិទ្ធកម្ម) ព្រមទាំងមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការសមស្រប។

# ១.ទិសដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់ប្រព័ន្ធថវិកា (២)

## តើប្រព័ន្ធថវិកា នៅឆ្នាំ២០២០ មានលក្ខណៈដូចម្តេច?

ដំណើរការនៃដំណាក់កាលទាំង ៤ នៃវដ្តថវិកានឹងត្រូវបានផ្លាស់ប្តូរនៅក្នុងប្រព័ន្ធទាំងមូល គឺ÷

**១-ការរៀបចំថវិកា:** ត្រូវផ្អែកលើគោលនយោបាយ កម្មវិធី និងសូចនាករ ដែលមានក្របខ័ណ្ឌគតិយុត្ត និងយន្តការច្បាស់លាស់ក្នុងការ ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងអាចវាស់វែងលទ្ធផល ដើម្បីធានាវិន័យថវិកា (តុល្យភាព/ និរន្តភាព) ប្រសិទ្ធភាពវិភាជ (វិភាជចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេស (ចំណាយប្រកបដោយស័ក្តិសិទ្ធភាព) ព្រមទាំងគោលការណ៍គ្រឹះទាំង ១១ នៃថវិកា។

**២-ការអនុម័តថវិកា:** ត្រូវផ្លាស់ប្តូរពីប្រភេទ ជំពូក ទៅជាគោលនយោបាយ កម្មវិធី និងសូចនាករ។

**៣-ការអនុវត្តថវិកា:** ធានាឱ្យមានការអនុវត្តថវិកាប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព ពិសេស គឺការផ្លាស់ប្តូរពីការតាមដាននិងវាយតម្លៃលើធាតុចូល ទៅជាការតាមដាននិងវាយតម្លៃលើធាតុចេញ។

**៤-ការត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនិងសមិទ្ធកម្ម:** ធានាឱ្យមានតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីអាចអនុវត្តក្របខ័ណ្ឌ និងយន្តការតាមដានវាយតម្លៃលទ្ធផល និងការគ្រប់គ្រងផ្តោតលើធាតុចេញ (វិសហមជ្ឈការ/វិមជ្ឈការ) ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

# ១.ទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកា (៣)

## តើត្រូវធ្វើយ៉ាងដូចម្ដេចទើបអាចឆ្ពោះទៅរកប្រព័ន្ធថវិកា នៅឆ្នាំ២០២០បាន?

បន្តពង្រឹងភាពជឿទុកចិត្តលើថវិកា និងបង្កើនជាបណ្ដើរៗគណនេយ្យភាពហិរញ្ញវត្ថុ និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមទាំងត្រៀមអនុវត្តគណនេយ្យភាពសមិទ្ធកម្ម គឺ÷

➢ **ផែនការសកម្មភាព ដែលត្រូវបញ្ចប់ដំណាក់កាលទី២ (២០១៥):**

- បន្តពង្រឹង និងបង្កើនស្ថិរភាព នៃភាពជឿទុកចិត្តនៃថវិកា (ចង្កោមសកម្មភាពគន្លឹះ ៤)។
- បន្តជំរុញការងារត្រៀមលក្ខណៈសម្រាប់ការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ជំហានទី១ ឆ្នាំ ២០១៥ និងពង្រឹងការអនុវត្តក្នុងឆ្នាំ២០១៥ ដើម្បីឈានទៅអនុវត្តពេញលេញនៅឆ្នាំ២០១៦ (មាតិកាថវិកាថ្មី ប្លង់គណនីថ្មី កិច្ចដំណើរការ នៃការអនុវត្តថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍)
- ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី (ពេញលេញសម្រាប់ក្រសួង ១០ នៅឆ្នាំ២០១៥ និង ក្រសួង ១៥ នៅឆ្នាំ២០១៦)។
- បន្តជំរុញការត្រៀមលក្ខណៈសម្រាប់ការដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា។
- បន្តជំរុញការកែលម្អ និងវាយតម្លៃការអនុវត្ត ព្រមទាំងរៀបចំត្រៀមលក្ខណៈ សម្រាប់ដាក់ផែនការយុទ្ធសាស្ត្រថវិកាឆ្លងគណៈរដ្ឋមន្ត្រី។

# ១.ទិសដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់ប្រព័ន្ធថវិកា (៤)

## តើត្រូវធ្វើយ៉ាងដូចម្តេចទើបអាចឆ្ពោះទៅរកប្រព័ន្ធថវិកា នៅឆ្នាំ២០២០បាន?

បន្តពង្រឹងភាពជឿទុកចិត្តលើថវិកា និងបង្កើនជាបណ្តើរៗគណនេយ្យភាពហិរញ្ញវត្ថុ និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមទាំងត្រៀមអនុវត្តគណនេយ្យភាពសមិទ្ធកម្ម គឺ÷

- **២០១៦-២០១៨÷ បន្តកែលម្អ ពិនិត្យឡើងវិញ និងរៀបចំលក្ខណៈសម្បត្តិ សម្រាប់ការអនុវត្តពេញលេញ** (ផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី, អង្គភាពថវិកា, មាតិកាថវិកាថ្មី, ប្លង់គណនីថ្មី,កិច្ចដំណើរការនៃការអនុវត្តថវិកាថ្មី ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និង**វិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ**)។
- **២០១៩-២០២០÷ ដាក់ឱ្យអនុវត្តពេញលេញថវិកាកម្មវិធី (ការផ្លាស់ប្តូរប្រព័ន្ធថវិកា និងការគ្រប់គ្រងទាំងមូល)។**

# ២. ផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកា

# ទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងរចនាសម្ព័ន្ធគោលនយោបាយ

## ការផ្សារភ្ជាប់រវាងថវិកាប្រចាំឆ្នាំ ទៅនឹងគោលនយោបាយថ្នាក់ជាតិនឹងត្រូវបានធានា

**គោលនយោបាយជាតិ**
(យុទ្ធសាស្ត្រចតុកោណ/ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ)

គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច/
គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

គោលនយោបាយតាមវិស័យ

ក្របខ័ណ្ឌចំណូល និងចំណាយ រយៈពេលមធ្យម

ផែនការយុទ្ធសាស្ត្រថវិកា

**ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ**

# ទំនាក់ទំនងរវាងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងរចនាសម្ព័ន្ធគោលនយោបាយ

...ការផ្សារភ្ជាប់រវាងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងរចនាសម្ព័ន្ធគោលនយោបាយនឹងត្រូវធានាជាមួយនឹងប្រព័ន្ធគណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់នឹងត្រូវបានអនុវត្ត...

| រចនាសម្ព័ន្ធគ្រប់គ្រង | សិទ្ធអំណាច និងការទទួលខុសត្រូវ | រចនាសម្ព័ន្ធគោលនយោបាយ |
|---|---|---|
| កម្រិតដឹកនាំ និងកំណត់គោលនយោបាយ (កម្រិតទី១: ក្រសួងស្ថាប័ន) | កំណត់គោលនយោបាយ | គោលបំណងគោលនយោបាយ/ យុទ្ធសាស្ត្រ/ កម្មវិធី |
| កម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់ យុទ្ធសាស្ត្រ/ កម្មវិធី (កម្រិតទី២: អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន) | កំណត់យុទ្ធសសាស្ត្រ/ កម្មវិធី | យុទ្ធសាស្ត្រ/ កម្មវិធី |
| កម្រិតបច្ចកទេស និងកំណត់ អនុកម្មវិធី/ ចង្កោមសកម្មភាព (កម្រិតទី៣: នាយកដ្ឋាន / សមមូល) | កំណត់អនុកម្មវិធី/ ចង្កោមសកម្មភាព | អនុកម្មវិធី/ ចង្កោមសកម្មភាព |
| កម្រិតបច្ចេកទេស និងអនុវត្តសកម្មភាព (កម្រិទី៣/៥...: បណ្តាអង្គភាពក្រោមឱវាទ) | កំណត់/អនុវត្តសកម្មភាព | សកម្មភាព |

# ការផ្លាស់ប្តូរមូលដ្ឋាននៃការរៀបចំថវិកា និងអនុម័តថវិកា

| មូលដ្ឋានបច្ចុប្បន្ន | | មូលដ្ឋានថ្មី | | |
|---|---|---|---|---|
| ប្រភេទ/ជំពូក | តម្រូវការថវិកា (លានរៀល) | គោលនយោបាយ | សូចនាករ/គោលដៅ | តម្រូវការថវិកា (លានរៀល) |
| **ប្រភេទ ១** | **១០០ ០០០** | **(១) គោលនយោបាយទី១** | សូចនាករទី១:<br>សូចនាករទី២: | **៩៤ ០០០** |
| ***៦០*** | ***៤១ ០០០*** | ***១.១- កម្មវិធីទី ១*** | សូចនាករទី១:<br>សូចនាករទី២: | ***៤៧ ០០០*** |
| ***៦១*** | ***១៤ ០០០*** | ១.១.១- អនុកម្មវិធី | | |
| ***៦២*** | ***១៣ ០០០*** | ១.១.១.១- ចង្កោមសកម្មភាព | | |
| ***៦៤*** | ***៣២ ០០០*** | ***១.២- កម្មវិធីទី ២*** | សូចនាករទី១:<br>សូចនាករទី២: | ***៤៧ ០០០*** |
| **ប្រភេទ ២** | - | ១.២.១- អនុកម្មវិធី | | |
| ***៦៦*** | - | ១.២.១.១- ចង្កោមសកម្មភាព | | |
| **ប្រភេទ ៣** | **២២ ០០០** | **(២) គោលនយោបាយទី២** | សូចនាករទី១:<br>សូចនាករទី២:<br>សូចនាករទី ៣: | **១៤១ ០០០** |
| ***៦៥*** | ***២២ ០០០*** | ***២.១- កម្មវិធីទី ៣*** | សូចនាករទី១:<br>សូចនាករទី២: | ***៤៧ ០០០*** |
| **ប្រភេទ ៤** | **១១៣ ០០០** | ២.១.១- អនុកម្មវិធី | | |
| ***៦៣*** | ***១១៣ ០០០*** | ២.១.១.១- ចង្កោមសកម្មភាព | | |
| | | ***២.២- កម្មវិធីទី ៤*** | សូចនាករទី១:<br>សូចនាករទី២: | ***៤៧ ០០០*** |
| | | ២.២.១- អនុកម្មវិធី | | |
| | | ២.២.១.១- ចង្កោមសកម្មភាព | | |
| | | ***២.៣- កម្មវិធីទី ៥*** | សូចនាករទី១:<br>សូចនាករទី២: | ***៤៧ ០០០*** |
| | | ២.៣.១- អនុកម្មវិធី | | |
| | | ២.៣.១.១- ចង្កោមសកម្មភាព | | |
| សរុប | ២៣៥ ០០០ | គោលនយោបាយ២/កម្មវិធី៥ | សូចនាករ ៥/១០ | ២៣៥ ០០០ |

# ៣. កត្តាកំណត់ជោគជ័យ

# ៣. កត្តាកំណត់ជោគជ័យ (១)

## ១- ការរៀបចំថវិកា

➢ ការរៀបចំថវិកាត្រូវបានកែលម្អមួយកម្រិត ពិសេសបន្ទាប់ពីការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការសាកល្បងថវិកាកម្មវិធី ព្រមទាំងការពង្រឹងការព្យាករណ៍ចំណូល និងការគណនាតម្រូវការចំណាយ។

➢ ប៉ុន្តែបញ្ហាប្រឈមគឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីមិនទាន់បានល្អ ហើយការព្យាករណ៍ចំណូល និងការគណនាតម្រូវការចំណាយមិនទាន់សុក្រឹត។

➢ ដូច្នេះ ***ត្រូវកែលម្អ និងពង្រឹងការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ព្រមទាំងបង្កើនសុក្រឹតភាពនៃការព្យាករណ៍ចំណូល និងការគណនាតម្រូវការចំណាយ*** ដើម្បីឱ្យការរៀបចំថវិកា ធានាបានការគោរពវិន័យថវិកាធានាបានការវិភាជថវិកាប្រកបដោយប្រសិទ្ធភាព និងធានាបាននូវស័ក្តិសិទ្ធភាពនៃចំណាយ។

# ៣. កត្តាកំណត់ជោគជ័យ (២)

## ២- ការអនុម័តថវិកា

- ការអនុម័តថវិកា ក៏ត្រូវបានកែលម្អមួយកម្រិត ពិសេសបន្ទាប់ពីការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការសាកល្បងថវិកាកម្មវិធី ព្រមទាំងការកែលម្អលើសេចក្តីព្រាងច្បាប់ តារាងឧបសម្ព័ន្ធ ព្រមទាំងកំណត់បង្ហាញ និងសេចក្តីថ្លែងហេតុ។
- ប៉ុន្តែបញ្ហាប្រឈមគឺការអនុម័តថវិកានៅតែផ្អែកលើគណនី ជំពូក ប្រភេទ ដោយសារផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលមានគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករ មិនទាន់ត្រូវបានអនុវត្តពេញលេញ និងយកមកធ្វើជាមូលដ្ឋានក្នុងការវិភាជ និងអនុម័តនៅឡើយ។
- ដូច្នេះ ត្រូវតែបន្តកែលម្អ និងពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ហើយឈានទៅអនុវត្តឱ្យបានពេញលេញ ***ដើម្បីឱ្យផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីក្លាយជាឧបករណ៍ ដ៏ពិតប្រាកដ និងយ៉ាងរឹងមាំសម្រាប់ការវិភាជ និងអនុម័តថវិកា។***

# ៣. ភាគ្លាកំណត់ជោគជ័យ (៣)

## ៣- ការអនុវត្តថវិកា

- ការអនុវត្តថវិកាពិតជាមានលក្ខណៈល្អប្រសើរច្រើន ពិសេសតាមរយៈការកាត់បន្ថយនីតិវិធីចំណាយ និងការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ និងការកែលម្អនីតិវិធីលទ្ធកម្មសាធារណៈ ព្រមទាំងការកែលម្អការទូទាត់ និងពង្រឹងការគ្រប់គ្រងសាច់ប្រាក់។
- ប៉ុន្តែ បញ្ហាប្រឈមគឺកិច្ចដំណើរការ នៃការអនុវត្តថវិកា (ការត្រួតពិនិត្យហិរញ្ញវត្ថុ ការធ្វើលទ្ធកម្មសាធារណៈ និងការទូទាត់) នៅតែស្មុគស្មាញ និងពុំទាន់ស្របទៅនឹងថវិកាកម្មវិធីនៅឡើយ។
- ដូច្នេះ ត្រូវតែបន្តកែលម្អកិច្ចដំណើរការ នៃការអនុវត្តថវិកាជាជំហានៗ ពិសេសតាមរយៈ ការដាក់ឱ្យអនុវត្តកិច្ចដំណើរការអនុវត្តថវិកាថ្មី, ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, ថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ដើម្បីឈានទៅអនុវត្ត ***ប្រព័ន្ធថវិកា និងការគ្រប់គ្រងផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម។***

# ៣. ភគ្គាកំណត់ជោគជ័យ (៤)

## ៤- ការត្រួតពិនិត្យនិងវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម

- ការត្រួតពិនិត្យនិងវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម មានវឌ្ឍនភាពតិចតួច រួមទាំងក្រសួងអនុវត្តថវិកាកម្មវិធី ដែលគុណភាពនៃការកំណត់សូចនាករ និងគោលដៅ ទៅតាមកម្មវិធី និងអនុកម្មវិធី នៅមានកម្រិត។
- បញ្ហាប្រឈម នៃការអនុវត្តប្រព័ន្ធថវិកា (ថវិកាកម្មវិធី) គឺ កង្វះប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មនិងលទ្ធផល ថែមទាំងមាន អសង្គតិភាពរវាងរចនាសម្ព័ន្ធស្ថាប័នគ្រប់គ្រង និងរចនាសម្ព័ន្ធគោលនយោបាយ, រីឯការរៀបចំប្រព័ន្ធនិងយន្តការការងារសម្រាប់ទ្រទ្រង់ថវិកាកម្មវិធី ក៏នៅមិនទាន់មានសមានគតិភាព នៅឡើយដែរ។
- ដូច្នេះ ***ទាមទារឱ្យមានការផ្លាស់ប្ដូរពីការត្រួតពិនិត្យនិងវាយតម្លៃលើធាតុចូល ទៅជាការត្រួតពិនិត្យនិងវាយតម្លៃលើធាតុចេញ/លទ្ធផល/សមិទ្ធកម្ម ហើយត្រូវបង្កើតប្រព័ន្ធ និងយន្តការត្រួតពិនិត្យនិងវាយតម្លៃលទ្ធផល និងសមិទ្ធកម្មឱ្យបានច្បាស់លាស់*** និងនៅគ្រប់លំដាប់ថ្នាក់ទាំងផ្ទៃក្នុង និងផ្ទៃក្រៅ រួមទាំងរវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។

# ៣. កត្តាកំណត់ជោគជ័យ (៥)

## ៥- ឆន្ទៈ សមត្ថភាព និងកិច្ចសហការ

- ***ឆន្ទៈ ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ បុរេសកម្ម និងស្មារតីទទួលខុសត្រូវ*** នៅមានកម្រិតដែលតម្រូវជាចាំបាច់ ឱ្យមានការពង្រឹង និងបង្កើនបន្ថែម។
- ***សមត្ថភាពស្ថាប័ន និងធនធានមនុស្ស*** នៅមិនទាន់សមស្របជាមួយនឹងប្រព័ន្ធថវិកាកម្មវិធី ទាំងនៅក្នុងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិប្បញ្ញត្តិ ដែលតម្រូវឱ្យមានការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពស្ថាប័នសម្រាប់រយៈពេលមធ្យម ប្រកបដោយសមានគតិភាពនិងប្រសិទ្ធភាព។
- ***កិច្ចសហការ និងសម្របសម្រួលស្ថាប័ន*** រវាងការកែទម្រង់ទាំង ៣ (ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) ត្រូវបានពង្រឹងបន្ថែមតាមរយៈយន្តការច្បាស់លាស់ ទាំងកម្រិតបច្ចេកទេស និងនយោបាយ។

# ៤. សន្និដ្ឋាន

# ៤. សន្និដ្ឋាន

១- លទ្ធផល បទពិសោធន៍ និងការត្រៀមលក្ខណៈបានល្អ គឺជាមូលដ្ឋានដ៏សំខាន់ និងរឹងមាំ ដែលធានាថា ការកែទម្រង់ដើរលើផ្លូវត្រូវ និងផ្តល់នូវជំនឿទុកចិត្តលើការអនុវត្តទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ទោះជាមានការលំបាក និងបញ្ហាប្រឈមខ្លះក៏ដោយ។

២- គ្មានជម្រើសផ្សេងទេ ការកែទម្រង់ជាការងារស្លាប់-រស់ ពិសេសក្នុងសម័យទំនើបកម្ម និងសមាហរណ-កម្ម ដែលបច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គមវិវត្តឥតឈប់ឈរ។

៣- ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះ អាចសម្រេចបាន ដោយផ្អែកលើមូលដ្ឋាននៃឆន្ទៈនយោបាយមោះមុត យន្តការដឹកនាំនិងគ្រប់គ្រងច្បាស់លាស់ ព្រមទាំងការចូលរួមអនុវត្តពីគ្រប់តួអង្គពាក់ព័ន្ធប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព។

៤- សមត្ថភាពស្ថាប័ននិងធនធានមនុស្ស ចាំបាច់ត្រូវពង្រឹងបន្ថែម ដើម្បីទ្រទ្រង់ការអនុវត្តប្រព័ន្ធថវិកាថ្មីប្រកបដោយជោគជ័យនិងចីរភាព។

ប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្ស  គឺជាកត្តាគន្លឹះកំណត់ជោគជ័យ ធានាវិន័យ តម្លាភាព គណនេយ្យភាព  ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

# សូមអរគុណ